**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រចេះ**

**ស្រុក ចិត្របុរី**

**ឃុំ កន្ទួត**

**លេខៈ** 800/16 ខ.ក.ក

# ដីកា

# ស្តីពី

# ការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការ អំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងលទ្ធផលសិក្ខាសាលាស្តីពី "វិធានការរួមស្តីពីការបង្ការ និងទប់ស្កាត់អំពើហិង្សាលើដៃគូស្និតស្នាលដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦។
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំកន្ទួតស្តីពីវិធានការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងចុះថ្ងៃទី...16... ខែ......11......ឆ្នាំ..2016...។

ដោយមើលឃើញថាបញ្ហា ដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និងប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋក្នុងឃុំកន្ទួត ដូច្នេះ ក្រុមប្រឹក្សាឃុំកន្ទួត

## សម្រេច

ប្រការ១៖ ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ និងបង្ការអំពើហិង្សាព្រមទាំងលើកកម្ពស់សុខុមាលភាព និងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជាការរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងឃុំកន្ទួតទាំងមូល។

ប្រការ២៖ ដីកានេះមានវិសាលភាពអនុវត្តទៅលើអ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬ បង្ករការរំខាន ឬបង្កហិង្សានានា ព្រមទាំងការលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យជន ឬនៅទីកន្លែងមួយចំនួនក្នុងឃុំកន្ទួតដែលបានកំណត់ក្នុងដីកានេះ។

ប្រការ៣៖ ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងដល់ប្រជាពលរដ្ឋ នៅក្នុងឃុំកន្ទួត តាមវិធីផ្សេងៗដូចជា ការជួបជុំបងប្អូន មិត្តភក្តិ ជាពិសេសកម្មវិធីប្រជុំ និងវេទិកាផ្សេងៗនៅក្នុងសហគមន៍។

ប្រការ៤៖ ព្រះសង្ឃ ដូនជី អាចារ្យ និងចាស់ព្រឹទ្ធាចារ្យចូលរួមក្នុងបង្កើនការអប់រំដល់អ្នកប្រើប្រាស់គ្រឿងស្រវឹងនៅក្នុង សហគមន៍ និងពិធីបុណ្យផ្សេងៗ។

ប្រការ៥៖ បញ្ចូលកម្មវិធី ការទប់ស្កាត់ អំពើហិង្សាលើដៃគូស្និទ្ធស្នាល ដោយសារគ្រឿងស្រវឹងចូលទៅក្នុងកម្មវិធីវិនិយោគ ឬផែនការអភិវឌ្ឍន៍ឃុំកន្ទួត។

ប្រការ៦៖ បញ្ឈប់ការផ្សព្វផ្សាយ និងលក់គ្រឿងស្រវឹងនៅតាមរបង និងក្នុងសាលារៀន វត្តអារ៉ាម និងអាគារសាធារណៈរបស់រដ្ឋ។

ប្រការ៧៖ ហាមសេពគ្រឿងស្រវឹងនៅក្នុងវត្តអារ៉ាម សាលារៀន សាលាឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាល និងរបងអាគារសាធារណៈរបស់រដ្ឋ។

ប្រការ៨៖ ហាមផ្សព្វផ្សាយរូបភាព ឬ ធ្វើសកម្មភាពបង្ខិតបង្ខំ ឬ ការជម្រុញលើកទឹកចិត្តក្មេងអាយុក្រោម ១៨ឆ្នាំអោយសេពគ្រឿងស្រវឹងនៅក្នុងសហគមន៍។

ប្រការ៩៖ ហាមសេពគ្រឿងស្រវឹងដែលបង្កសំលេងរំខានដល់អ្នកដទៃចាប់ពីម៉ោង១១យប់ឡើងទៅ និងការបង្កភាពឥតសណ្តាប់ធ្នាប់នៅទីសាធារណៈផ្សេងៗក្នុងឃុំ។

ប្រការ១០៖ ហាមលក់គ្រឿងស្រវឹងអោយអតិថិជនដែលស្ថិតក្នុងស្ថានភាពស្រវឹង។

ប្រការ១១៖ អាជ្ញាធរត្រូវហៅអ្នកប្រព្រឹត្តផ្ទុយពីប្រការ៦, ប្រការ៧, ប្រការ៨, ប្រការ៩ និងប្រការ១០ ដើម្បីធ្វើការអប់រំ និងណែនាំដោយមានកិច្ចសន្យា។ ក្នុងករណី០៣លើក អ្នកប្រព្រឹត្តនៅតែមិនអនុវត្តតាមការណែនាំរបស់អាជ្ញាធរ នឹងត្រូវធ្វើការផាកពិន័យនៅលើកទី០៤ ជាប្រាក់ចំនួន ១០.០០០រៀល និងលើកទី០៥ ចំនួន១.០០០.០០០រៀល ឬចាត់វិធានការតាមច្បាប់ជាធរមាន។

ប្រការ១២៖ ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅឃុំកន្ទួត, ថ្ងៃទី......ខែ...11......ឆ្នាំ២០១៦

មេឃុំ

ស៊ុខ_ផល

<u>ចម្លងជូន</u>

- សាលាស្រុកចិត្របុរី (ដើម្បីជូនជ្រាប)
- ក្រុមប្រឹក្សាឃុំ, ប៉ុស្តិ៍នគរបាល, មេភូមិ និងក្រុមបណ្តាញទាំងអស់ (ដើម្បីអនុវត្ត)
- ឯកសារកាលប្បវត្តិ